# សាលាបឋមសិក្សា សោថហ្វក (SOUTHWARK)

1835 S. 9th Street
Philadelphia, PA 19148
**ការិយាល័យ៖ 215-952-8606**
**ទូរសារ៖ 215-952-8670**

**Andrew Lukov**, នាយកសាលា

## ច្បាប់ឯកសណ្ឋានរបស់សាលាបឋមសិក្សា សោថហ្វក

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានអនុម័តច្បាប់ឯកសណ្ឋានសម្រាប់សិស្សានុសិស្សទាំងអស់។ សិស្សានុសិស្ស ថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី៥ ទាំងអស់ របស់សាលា សោថហ្វក ចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន ដូចតទៅនេះ៖

- ខោ/សំពត់ កាគី ពណ៌ដាំដែង
- អាចស្លៀកខោកៅស៊ូពណ៌លាត ទឹកប៊ិចចាស់បានតែនៅថ្ងៃ ហាត់ប្រាណ និង/ឬ ថ្ងៃរាំ តែប៉ុណ្ណោះ។
- អាចពាក់អាវម៉ូដ ប៉ូឡូ ឬ អាវយឺត ពណ៌លាត ទឹកប៊ិចចាស់ – មិនអនុញ្ញាតឲ្យមាន រូបសញ្ញា និង/ឬ ក្បាច់រចនា ទេ
- អាវរងារពណ៌លាតទឹកប៊ិចចាស់ សម្រាប់ធាតុអាកាសត្រជាក់ - មិនអនុញ្ញាតឲ្យមាន រូបសញ្ញា និង/ឬ ក្បាច់រចនា ទេ

សិស្សានុសិស្ស ថ្នាក់៦ ដល់ ថ្នាក់ទី៨ ទាំងអស់ របស់សាលា សោថហ្វក ចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន ដូចតទៅនេះ៖

- អាវពណ៌ខៀវខ្ចី Official Upper School (លក់នៅសាលា)
- សំពត់ ឬ ខោ ពណ៌ ដាំដែង ខ្មៅ ឬ ខៀវ (ខោ ឬ ខោខូវប៊យ) (ហាមស្លៀកបា ខោរិប/ No leggings)
- អាចស្លៀកខោកៅស៊ូពណ៌លាតខៀវបានតែនៅថ្ងៃ ហាត់ប្រាណ និង/ឬ ថ្ងៃរាំ តែប៉ុណ្ណោះ។
- បើសិនជាកូនលោកអ្នកមិនស្លៀកពាក់ឯកសណ្ឋានរបស់សាលាទេ គេនឹងឲ្យអាវទៅពួកគេពាក់នៅថ្ងៃនោះ។ បើសិនជាមិនប្រគល់អាវនោះឲ្យសាលាវិញនៅពេលចប់ម៉ោងរៀន សាលានឹងទារថ្លៃ $១០។

គឺមានទំនាក់ទំនងយ៉ាងច្បាស់លាស់រវាង ទម្លាប់ស្លៀកពាក់ល្អ ទម្លាប់ធ្វើការល្អ និង អាកប្បកិរិយាត្រឹមត្រូវនៅសាលា។ ដើម្បីលើកកម្ពស់ទំនាក់ទំនងល្អនេះ សាលាបានអនុម័តបទបញ្ញត្តិដែលទាក់ទងនឹងការស្លៀកពាក់ត្រឹមត្រូវ សម្រាប់សិស្សានុសិស្សទាំងអស់ ដូចតទៅនេះ៖

- មិនត្រូវពាក់អាវមានមួកគ្របក្បាលទៅរៀន ហើយមិនអនុញ្ញាតឲ្យពាក់ចូលក្នុងអាគារសាលាទេ
- មិនត្រូវពាក់ មួក ឈ្នួតក្បាល ក្រវាត់ក្បាលទប់ញើស (sweat bands) មួកកាតឹប ប្រដាប់មូរសក់ និង កន្សែងជួតក្បាល នៅក្នុងអាគារទេ។ គឺសម្រាប់ទាំងស្រី ទាំងប្រុស។ (មានការលើកលែងចំពោះមូលហេតុសាសនា)។ បើពាក់មួកនៅក្នុងអាគារ គេនឹងដកហូតយកមួក។
- មិនអនុញ្ញាតឲ្យពាក់ ស្បែកជើងដែលចេញម្រាមជើង ត្រនាប់ជើងពាក់នៅផ្ទះ ស្បែកជើងផ្ទាត់ ស្បែកជើងប៉ាតាដែលមានកង់ និង ស្បែកជើងសង្រែក ទេ។
- មិនត្រូវស្លៀក ខោខ្លី សំពត់ខ្លី ឬសម្លៀកបំពាក់ដែលខើច បី (៣) អ៊ិញ លើជង្គង់ ទេ។ មិនអាចមូរជើងខោ មិនអាចស្លៀកខោសំយេះក្រោមចង្កេះបានទេ។
- មិនត្រូវពាក់ អាវយឺតអត់ដៃ អាវចងពង់ ឬ អាវដែលអាចមើលឃើញសាច់ បង្ហាញផ្នែកនៃរាងកាយណាមួយ ទេ។
- គេមិនអនុញ្ញាតឲ្យស្លៀកខោដែលរហែកខ្លាំងពេកទេ។
- មិនត្រូវពាក់ វ៉ែនតាខ្មៅ នៅក្នុងអាគារ។
- គ្រឿងអលង្ការដែលធំ និង/ឬ ថ្លៃៗ មិនសមរម្យនឹងពាក់មកសាលាទេ ហើយគប្បីទុកនៅផ្ទះ។

ការមករៀនមិនពាក់ឯកសណ្ឋានគឺជាបទល្មើសនឹងច្បាប់របស់សាលា។ គេនឹងទាក់ទងទៅ មាតាបិតា/អាណាព្យាបាល នៅពេលណាក្មេងមិនពាក់ឯកសណ្ឋានមកសាលា។ យោងទៅលើសម្លៀកបំពាក់របស់កូនលោកអ្នក គេអាចសុំឲ្យលោកអ្នកយកឯកសណ្ឋាន សមរម្យមកឲ្យកូននៅសាលាជាបន្ទាន់។ សិស្សដែលប្រព្រឹត្តិល្មើសនឹងបទវិន័យនេះម្តងហើយម្តងទៀត នឹងទទួលការដាក់វិន័យនៅសាលា។